# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៥ ស.ស.រ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតក្រុមការងារបច្ចេកទេសទទួលបន្ទុករៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រ សំរាប់អភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ពត៌មានវិទ្យា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកត/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៨០០/១៥២ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យា គមនាគមន៍ ពត៌មានវិទ្យា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៥០៣/១៦៩ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០២ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមរយៈសញ្ជាតូបនីយកម្មជូនអ្នកស្រី ហៅឡែន ចារីស
- បានឃើញអនុក្រឹត្យលេខ ៥០អនក្រ. បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីការបង្កើត ក្រុមការងារជាន់ខ្ពស់ដើម្បីដឹកនាំសំរបសំរួល និងរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រជាតិសំរាប់អភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ពត៌មានវិទ្យា
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

# សំ រេ ច

**ប្រការ១** : ចាត់តាំងមន្ត្រីនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យា គមនាគមន៍ ពត៌មានវិទ្យា និងតំណាងក្រសួងពាក់ពន្ធ័ ដើម្បីចូលរួមជាសមាសភាពក្រុមការងារបច្ចេកទេសរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រ និងទំនាក់ទំនងការងារជាមួយតំណាងស្ថានទូតនានាប្រចាំនៅកម្ពុជា អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និង អន្តរជាតិ ក្រុមហ៊ុនឯកជន ស្ថាប័នពាក់ពន្ធ័ និងអ្នកស្រាវជ្រាវជាតិ ដូចខាងក្រោម :

**១- ផ្នែកសំរបសំរួលនិងប្រមូលសរុបឯកសារគោលនយោបាយ និងយុទ្ធសាស្ត្រ(Policy and Strategy):**

| | | |
|---|---|---|
| - ឯកឧត្តម សេង លឹមនៅ | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| - ឯកឧត្តម ឆឹយ រឿន | អគ្គលេខាធិការរងរាជរដ្ឋាភិបាល | អនុប្រធាន |
| - បណ្ឌិត ហៅឡែន ចារីស | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| - បណ្ឌិត ណាត ប៊ុនរឿន | ប្រធាននាយកដ្ឋានបណ្តុះបណ្តាលគ្រូក្រសួងអប់រំយុវជននិងកីឡា | អនុប្រធាន |
| - ឯកឧត្តម អ៊ឹង វុទ្ធី | ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - លោក មាស កុសល | NiDA | សមាជិកអចិន្ត្រៃយ៍ |
| - លោក ជុន វ៉ាត | NiDA | សមាជិក |
| - លោក ហួរ វិសាល | ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - លោក ញ៉ូ បណ្ឌូល | NiDA | សមាជិក |
| - លោក បញ្ញា អ៊ិន | NiDA | សមាជិក |
| - លោក ហ៊ីន សិរិទ្ធី | NiDA | សមាជិក |
| - កញ្ញា ចន្ទ័ រាសីភក្តិ | NiDA | សមាជិក |
| - លោក គិត ចន្ទ័ត្រីស្នា | NiDA | សមាជិក |
| - លោក ទូច សំណាង | NiDA | សមាជិក |

**២- ផ្នែកហេដ្ឋារចនាសម្ព័ន្ធ (Infrastructure)**

| | | |
|---|---|---|
| - ឯកឧត្តម ឡា ណារ៉ាត | អនុរដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | ប្រធាន |
| - លោក ឡាយ ម៉ារីវ៉ូ | អគ្គនាយករង អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | អនុប្រធាន |
| - លោក កែវ ផាន់ណារិន | ប្រធានការិយាល័យ IT ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| - លោក វណ្ណ ខែមម៉ា | NiDA | សមាជិកអចិន្ត្រៃយ៍ |
| - លោក ម៉ប់ ចន្ទ័កិរក្ស | NiDA | សមាជិក |

| | | | |
|---|---|---|---|
| - | លោក យឹម សូ | NiDA | សមាជិក |
| - | លោក កែវ សេរីវុឌ្ឍ | NiDA | សមាជិក |
| - | លោក ហ៊ីន សិទ្ធី | NiDA | សមាជិក |
| - | លោក ផៅ ឡាំ | NiDA | សមាជិក |
| - | លោក មាស សុខជា | NiDA | សមាជិក |
| - | លោក ភូ ស៊ីហេុច | NiDA | សមាជិក |

**៣- ផ្នែកបណ្តុះបណ្តាលសមត្ថភាពធនធានមនុស្ស (Human Capacity)**

| | | | |
|---|---|---|---|
| - | ឯកឧត្តម អ៊ឹម សិទ្ធី | រដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា | ប្រធាន |
| - | លោក អ៊ុក ឈឿង | នាយកដេប៉ាតឺម៉ង់កុំព្យូទ័រ សាកលវិទ្យាល័យភ្នំពេញ | អនុប្រធាន |
| - | លោក ជុន វ៉ាត | NiDA | សមាជិកអចិន្ត្រៃយ៍ |
| - | លោក សុខ តាក់ | NiDA | សមាជិក |
| - | លោក ឡុង ហាន | NiDA | សមាជិក |
| - | លោក គី សៅរិទ្ធ | NiDA | សមាជិក |
| - | លោក ឈាង ប៊ុនថេន | NiDA | សមាជិក |
| - | កញ្ញា មាស មករា | NiDA | សមាជិក |

**៤- ផ្នែកបរិស្ថានគោលនយោបាយ (Policy Environment)**

| | | | |
|---|---|---|---|
| - | ឯកឧត្តម សំ សុផល | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| - | លោក ម៉េង គឹមហ៊ី | ប្រធានការិយាល័យអភិវឌ្ឍន៍កុំព្យូទ័រ ក្រសួងផែនការ | អនុប្រធាន |
| - | លោក អាន វ៉ា | NiDA | សមាជិកអចិន្ត្រៃយ៍ |
| - | លោក ញ៉ូ បណ្ឌូល | NiDA | សមាជិក |
| - | លោក អ៊ូង សារ៉ាត់ | NiDA | សមាជិក |
| - | លោក ពាង តុលា | NiDA | សមាជិក |
| - | លោក អែតជា ជូរ៉ាមី | NiDA | សមាជិក |
| - | លោក នួន មុនីរត្ន័ | NiDA | សមាជិក |

**៥- ផ្នែកកសាងកម្មវិធី និងខ្លឹមសារ (Contents and Application)**

| | | | |
|---|---|---|---|
| - | បណ្ឌិត ចន្ទ័ រ័ត្ន | សមាជិករាជបណ្ឌិតសភាកម្ពុជា | ប្រធាន |
| - | លោក ម៉ូវ ចរិយា | អនុប្រធាននាយកដ្ឋាននិយ័ត និងទំនាក់ទំនងអន្តរជាតិ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | អនុប្រធាន |
| - | លោក ឈួន វ៉ន់ | NiDA | សមាជិកអចិន្ត្រៃយ៍ |

| | | |
|---|---|---|
| - លោក សួង ណាយ | NiDA | សមាជិក |
| - លោក បញ្ញា អ៊ិន | NiDA | សមាជិក |
| - លោក អែតដា នីរ៉ាវណ្ណ | NiDA | សមាជិក |
| - លោក ផន សុភាព | NiDA | សមាជិក |

**<u>៦- ផ្នែកអភិវឌ្ឍន៍សហគ្រាស (Enterprise)</u>**

| | | |
|---|---|---|
| - ឯកឧត្តម សុក ស៊ីផាន់ណា | រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | ប្រធាន |
| - ឯកឧត្តម សុខ ចិន្តា សូភា | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| - លោក ថាន់ សុជាតិ | NiDA | សមាជិកអចិន្ត្រៃយ៍ |
| - លោក ទូច គឹមហ៊ុយ | NiDA | សមាជិក |
| - លោក គុប ចាន់រី | NiDA | សមាជិក |
| - លោក ទេព កោសល្យ | NiDA | សមាជិក |
| - លោក លន់ ចន្ទ័បូរី | NiDA | សមាជិក |
| - កញ្ញា សេង បូរី | NiDA | សមាជិក |
| - លោក គិត ចន្ទ័ត្រឹស្នា | NiDA | សមាជិក |
| - លោក រស់ សីហា | NiDA | សមាជិក |

**ប្រការ២** : ក្រុមការងារបច្ចេកទេសខាងលើទទួលបន្ទុកផ្នែកបច្ចេកទេសរៀងៗខ្លួន ដើម្បីរៀបចំឯកសារគោលនយោបាយ និងយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ពត៌មានវិទ្យា ក្រោមការដឹកនាំចង្អុលបង្ហាញទិសរបស់ក្រុមការងារជាន់ខ្ពស់ ។

គ្រប់ផ្នែកបច្ចេកទេសទាំងអស់ត្រូវរៀបចំរបាយការណ៍ដាក់ជូនផ្នែកសំរបសំរួល និងបូកសរុបឯកសារគោលនយោបាយ និងយុទ្ធសាស្ត្រ ។

គ្រប់ផ្នែកបច្ចេកទេសទាំងអស់ត្រូវទំនាក់ទំនង និងសំរបសំរួលការងារជាមួយ :

- តំណាងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិដូចជា UNDP, World Bank, UNESCO, ADB USAID, AUSAID, JICA ។ល។
- តំណាងស្ថានទូតនានាប្រចាំនៅព្រះរាជាណាចក្រកម្ពុជាដូចជា សាធារណរដ្ឋកូរ៉េ សឹង្ហបូរី ជប៉ុន ឥណ្ឌា អាមេរិក ម៉ាឡេស៊ី ។ល។
- តំណាងក្រុមហ៊ុនឯកជននានាដូចជា Mobitel, Samart, Camshin, Cogetel Online, AZ Group ។ល។

**ប្រការ៣** : ក្រុមការងារបច្ចេកទេសនិមួយៗមានភារកិច្ចដូចតទៅ :

**<u>១- ផ្នែកសំរបសំរួល និងបូកសរុបឯកសារគោលនយោបាយ និងយុទ្ធសាស្ត្រ (Policy and Strategy):</u>**

- ផ្នែកសំរបសំរួលនិងប្រមូលសរុបឯកសារគោលនយោបាយ និងយុទ្ធសាស្ត្រស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រុមការងារជាន់ខ្ពស់ មានភារកិច្ចចាត់ចែង និងត្រួតពិនិត្យសកម្មភាពប្រតិបត្តិការចាំបាច់ប្រចាំថ្ងៃ ដើម្បីធ្វើឱ្យសំរេចលទ្ធផលតាមការគ្រោងទុករបស់គំរោង ។
- ទំនាក់ទំនងជាមួយប្រធានផ្នែកទាំងអស់ និងដើរតួនាទីជាអ្នកសំរបសំរួលការងាររវាងក្រុមការងារជាន់ខ្ពស់ ក្រុមអ្នកស្រាវជ្រាវជាតិ និងគ្រប់ផ្នែកទាំងអស់ ដើម្បីធានាឱ្យមានភាពស៊ីសង្វាក់នូវកិច្ចទំនាក់ទំនង និងការពិភាក្សារវាងសមាជិកក្រុមការងារទាំងអស់ប្រព្រឹត្តទៅបានល្អ ។
- គ្រប់គ្រងហិរញ្ញវត្ថុ និងរៀបចំការប្រជុំកំពូលជាផ្លូវការស្តីពីការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រ និងកិច្ចពិគ្រោះយោបល់កំរិតជាតិលើវិស័យ ICT ។
- រៀបចំកោះប្រជុំតាមការស្នើរបស់ក្រុមការងារជាន់ខ្ពស់ និងការប្រជុំចាំបាច់ដទៃទៀតដើម្បីដោះស្រាយបញ្ហាសំខាន់ៗ ។
- រៀបចំកាលវិភាគជួបជាមួយក្រុមការងារបច្ចេកទេស និងទទួលឯកសារចាំបាច់ពីគ្រប់ផ្នែកបច្ចេកទេស ។
- ទំនាក់ទំនងដើម្បីទទួលយកឯកសារចាំបាច់ពី ក្រុមអ្នកសំរបសំរួលអន្តរជាតិ និងជួយសំរួលការងារចាំបាច់របស់ពួកគេ ។

**២- ផ្នែកហេដ្ឋារចនាសម្ព័ន្ធ (Infrastructure):**

- បង្ហាញនូវហេដ្ឋារចនាសម្ព័ន្ធក្នុងបរិបទនៃយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍន៍វិស័យ ICT ជាអ្នកជួយសំរួលដល់គោលដៅអភិវឌ្ឍន៍ ។
- ទំនាក់ទំនង និងសំរបសំរួលការងារជាមួយតំណាងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ តំណាងស្ថានទូតនានាប្រចាំនៅកម្ពុជាដូចជាស្ថានទូតសាធារណរដ្ឋកូរ៉េ និងក្រុមហ៊ុននានាដូចជាក្រុមហ៊ុន Mobitel ជាដើម ។ល ។

**៣- ផ្នែកសមត្ថភាពធនធានមនុស្ស (Human Capacity)**

- បង្ហាញនូវការអភិវឌ្ឍន៍ផ្នែកចំណេះដឹងយ៉ាងឆាប់រហ័សដល់កម្មករ អ្នកប្រើប្រាស់បច្ចេកវិទ្យា សហគ្រិន ក្នុងគោលដៅចែកចាយបច្ចេកវិទ្យា ICT ដែលជាអ្នកជួយដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ។

**៤- ផ្នែកបរិស្ថានគោលនយោបាយ (Policy Environment)**

- ពិនិត្យលើបរិស្ថានគោលនយោបាយ តម្លាភាព ជាពិសេសបទបញ្ញត្តស្តីពីបរិស្ថានដែលប៉ះពាល់ដល់ការអភិវឌ្ឍន៍លើគ្រប់វិស័យ ។ ជាងនេះទៀត គោលនយោបាយជាគន្លឹះនៃវិស័យនិមួយៗ សំរាប់ផែនការយុទ្ធសាស្ត្រ សមត្ថភាពធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធ សហគ្រាស ក៏ដូចជាគោលនយោបាយសំរាប់គាំទ្រដល់ការប្រកួតប្រជែងសេរី និងច្បាប់កម្មសិទ្ធិបញ្ញា សុទ្ធសឹងមានសារៈសំខាន់ដល់ការយកមកប្រើប្រាស់នូវសក្តានុពល ICT ។

**៥- ផ្នែកកសាងកម្មវិធី និងខ្លឹមសារ (Contents and Application)**

- រៀបចំកម្មវិធី និងខ្លឹមសារ Content and Application សមស្រប ដើម្បីសំរេចគោលដៅអភិវឌ្ឍន៍ដែលពឹងផ្អែកលើសមត្ថភាព ICT ។
- ពិចារណាលើផ្នែកទំនាក់ទំនង និងការប្រើប្រាស់ ICT អំពីភាសា លទ្ធភាពប្រើប្រាស់ និងអភិវឌ្ឍន៍កម្មវិធី ។

**<u>៦- ផ្នែកអភិវឌ្ឍន៍សហគ្រាស (Enterprise)</u>**

- ដើរតួនាទីក្នុងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្នែកឯកជន ការបង្កើតការងារ និងជំរុញការអភិវឌ្ឍន៍ ។
- បង្កើតលក្ខខណ្ឌការងារដែលអាចទុកចិត្តបាន និងជួយទ្រទ្រង់សុខុមាលភាពដែលជាឬសគល់នៃការអភិវឌ្ឍន៍ ។
- ពិនិត្យលើផ្នែក និង/ឬផ្នែកបន្ទាប់បន្សំដូចជា ហិរញ្ញវត្ថុ និងឥណទាន កម្មសិទ្ធិបញ្ញា និងច្បាប់ពាណិជ្ជកម្មរបបពន្ធដា ការបើកចំហទីផ្សារ ការបង្កើនប្រសិទ្ធិភាព និងការធ្វើជំនួញក្នុងស្រុក ។ល ។

**ប្រការ៤** : ក្នុងករណីចាំបាច់ ប្រធានក្រុមការងារជាន់ខ្ពស់អាចតែងតាំងបំពេញបន្ថែមសមាជិកក្រុមការងារបច្ចេកទេសណាមួយតាមតំរូវការជាក់ស្តែង ។

**ប្រការ៥** : ឯកឧត្តមប្រធានក្រុមការងារជាន់ខ្ពស់ ឯកឧត្តមអគ្គលេខាធិការអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យា គមនាគមន៍ ពត៌មានវិទ្យា ឯ ឧត្តម អស់លោក លោកស្រី សមាសភាពក្រុមការងារបច្ចេកទេសដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវសហការទំនាក់ទំនងការងារជាមួយស្ថានទូតនានាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ស្ថាប័នផ្តល់ជំនួយ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ក្រុមហ៊ុនឯកជន អនុវត្តតាមខ្លឹមសារនៃសេចក្តីសំរេចនេះឱ្យបានសំរេចប្រកបដោយតម្លាភាព និងចូលរួមជាអតិបរិមាពីភាគី ឬស្ថាប័នពាក់ព័ន្ធចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>ចំលងជូន :</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ